**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២.៥៦៧ ហិកតា នៅស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វ័ត្តសម្បត្តិ និងកាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៧៦ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់ នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤១៣/៣៧៩ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សា គោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយ ខុសច្បាប់
- លិខិតលេខ ៤២២ ខបប ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ២.៥៦៧ ហិកតា ក្នុងនោះ (១) ទំហំ ១.៤១៤,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស តាមព្រះរាជក្រឹត្យ លេខ នស/រកត/០៤១៣/៣៧៩ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៣ (២) ទំហំ ៩១៦ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុនយូរីសាគរ (៣) ទំហំ ១០០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនវ័ត្នសម្បត្តិ និង (៤) ទំហំ ១៣៦,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ២.៥០២,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៧៦ គ្រួសារ និង ៦៤,៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ដីភ្នំ) នៅឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ១៤១,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរនរនោង
- កាត់ផ្ទៃដីសរុបទំហំ ៨២៤ ហិកតា ក្នុងនោះ (១) ទំហំ ៤០៨,៥ ហិកតា កាត់ចេញពីដែន ជម្រកសត្វព្រៃភ្នំសំកុស (២) ទំហំ ៣០៧,៥ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ ក្រុមហ៊ុន យូរីសាគរ និង (៣) ទំហំ ១០៨ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សី

របស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្ម ៧៥៩,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៥,៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ដីភ្នំ) នៅភូមិអូរក្រូច

- ផ្ទៃដីទំហំ ៩៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរគ្រែង
- ផ្ទៃដីទំហំ ១១៣,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨២ គ្រួសារ នៅភូមិពាមតា
- ផ្ទៃដីទំហំ ១៦៣,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិពាម
- កាត់ផ្ទៃដីសរុបទំហំ ៨៣២,៥ ហិកតា ក្នុងនោះ (១) ទំហំ ១០៦ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស (២) ទំហំ ៥៩៨ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ (៣) ទំហំ ១០០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វត្តសម្បត្តិ និង (៤) ទំហំ ២៨,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មទំហំ ៨៣២,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរតាទៀក
- កាត់ផ្ទៃដីសរុបទំហំ ២៣៩,៥ ហិកតា ក្នុងនោះ (១) ទំហំ ២២៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស (២) ទំហំ ១០,៥ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិតាតោក
- ផ្ទៃដីទំហំ ១៦២,៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិវាលរលឹម

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ២.៩៧៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៨ គ្រួសារ នៅភូមិអូរនេនោង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣១០ គ្រួសារ នៅភូមិអូរក្រូច
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥១ គ្រួសារ នៅភូមិអូរគ្រែង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨២ គ្រួសារ នៅភូមិពាមតា
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៣ គ្រួសារ នៅភូមិពាម
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩៧ គ្រួសារ នៅភូមិអូរតាទៀក

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១២៥ គ្រួសារ នៅភូមិតាគោក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១២០ គ្រួសារ នៅភូមិវាលរលឹម ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាតទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*